# បរិយាបន្នសម្រាប់ជនមានពិការភាព

## ដំណោះស្រាយដើម្បីបង្កើនការចូលរួមរបស់ជនមានពិការភាព

USAID FROM THE AMERICAN PEOPLE

fhi360

agile

ឌីជីថល សម្រាប់ទាំងអស់គ្នា DIGITAL FOR ALL

# មាតិកា

មាតិកា
I. សវតានៃគម្រោង 2
II. គោលដៅ និងគោលបំណង 2
a. គោលដៅ 2
b. គោលបំណង 3
III. ការផ្លាស់ប្តូរបរិបទនៃគម្រោង 3
IV. លទ្ធផល 3
a. ការអប់រំសម្រាប់ជនមានពិការភាព 4
ការធ្វើដំណើរ 4
ការបង្កលក្ខណៈងាយស្រួល 5
លទ្ធភាពទទួលបានព័ត៌មាន 6
លទ្ធភាពឌីជីថល 6
សមត្ថភាពបង្រៀន 7
សុខភាពផ្លូវកាយ ផ្លូវចិត្ត និងសុខមាលភាព 8
b. អត្ថប្រយោជន៍សង្គមសម្រាប់ជនមានពិការភាព 9
លទ្ធភាពទទួលបានព័ត៌មាន 9
លទ្ធភាពឌីជីថល 10
ការរើសអើងក្នុងសង្គម 11
សមត្ថភាពសម្របសម្រួលសេវាកម្ម 11
ផាសុកវត្ថុ 12
c. សេវាស្តារនីតិសម្បទាសម្រាប់ជនមានពិការភាព 13
លទ្ធភាពក្នុងការធ្វើដំណើរ 13
លទ្ធភាពទទួលបានព័ត៌មាន 14
ជំនឿផ្ទាល់ខ្លួន និងឥទ្ធិពលនៃបរិយាកាសជុំវិញ 15
សមត្ថភាពសម្របសម្រួលរបស់អ្នកផ្តល់សេវា 15
d. លទ្ធភាពទទួលបានការងារសម្រាប់ជនមានពិការភាព 16
ឧបសគ្គសង្គម និងឧបសគ្គស្ថាប័ន 16
ផាសុកវត្ថុ 17
លទ្ធភាពទទួលបានព័ត៌មាន 17
ចំណេះដឹងអំពីពិការភាព 18
ជំនាញផ្ទុយទៅនឹងទីផ្សារការងារ 18
សេចក្តីបញ្ចប់ 20

# ដំណោះស្រាយប្រមូលផ្តុំនៃគម្រោង «ឌីជីថលសម្រាប់ទាំងអស់គ្នា: ការចូលរួមរបស់ជនមានពិការភាពតាមរយៈប្រព័ន្ធឌីជីថល»

## I. សវតានៃគម្រោង

កត្តាជាច្រើនបានជះឥទ្ធិពលលើសមត្ថភាពរបស់ជនមានពិការភាពក្នុងការចូលរួមយ៉ាងពេញលេញ និងស្មើភាពគ្នាដូចជា កត្តាផ្ទាល់ខ្លួន លក្ខខណ្ឌរស់នៅ និងការងារ កត្តាសេដ្ឋកិច្ចសង្គម វប្បធម៌ បរិស្ថាន និងការទទួលបានសេវាថែទាំសុខភាពជាដើម។ យោងតាមរបាយការណ៍ពិភពលោកស្តីពីពិការភាព (២០១១) នៅទូទាំងពិភពលោក ជនមានពិការភាពជាច្រើនប្រឈមមុខនឹងភាពក្រីក្របើប្រៀបធៀបទៅនឹងជនដែលគ្មានពិការភាព។[1]

រាជរដ្ឋាភិបាលកម្ពុជាកំពុងដាក់ចេញនូវគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២២-២០៣៥ ក្នុងគោលបំណងកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលដ៏រស់រវើក។ ដើម្បីសម្រេចបាននូវចំណុចនេះ គោលនយោបាយដែលមានលក្ខណៈបរិយាបន្នមានសារៈសំខាន់ណាស់ដើម្បីធានាឲ្យមានការចូលរួមស្មើគ្នាសម្រាប់មនុស្សគ្រប់រូបរួមទាំងជនមានពិការភាពផងដែរ។ តាមរយៈការគិតគូរទៅលើផាសុកវត្ត និងបរិយាបន្នដូចជាការអនុវត្តគោលការណ៍រចនាជាសកល ការផ្តល់បច្ចេកវិទ្យាជំនួយ និងសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិពិការភាពទៅកាន់សាធារណជន កម្ពុជាអាចបង្កើតសង្គមមួយដែលមានភាពសមធម៌ អនុញ្ញាតឲ្យជនមានពិការភាពចូលរួមចំណែក និងរីកចម្រើនជាងមុន។

## II. គោលដៅ និងគោលបំណង

### a. គោលដៅ

គម្រោង «ឌីជីថលសម្រាប់ទាំងអស់គ្នា : ការចូលរួមរបស់ជនមានពិការភាពតាមរយៈប្រព័ន្ធឌីជីថល» មានគោលបំណងបង្កើនការចូលរួមរបស់ជនមានពិការភាពប្រកបដោយបរិយាបន្នដោយលើកកម្ពស់ការយល់ដឹងអំពីយុទ្ធសាស្ត្រចូលរួមរបស់ប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថល ជម្រុញឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ក៏ដូចជាជះ ឥទ្ធិពលទៅកាន់អ្នក

[1] Ministry of Social Affairs Veterans and Youth Rehabilitation, Disability Action Council, & National Institutes of Statistics. (2023). PERSONS WITH DISABILITIES IN CAMBODIA : FINDINGS FROM THE CAMBODIA DEMOGRAPHIC AND HEALTH SURVEY, 2014 & 2021-22. In *access2cambodia.org*. Retrieved July 9, 2024, from https://access2cambodia.org/ptoaftec/2024/02/Situational_Analysis_Persons_with_disabilities_in_Cambodia_Final.pdf

បង្កើតគោលនយោបាយអំពីអក្ខរកម្មឌីជីថល និងការសម្របសម្រួលសមរម្យសម្រាប់បរិយាបន្នជនមានពិការភាព។

### b. គោលបំណង

I. បង្កើតធាតុចូល និងយុទ្ធសាស្ត្រចូលរួមបែបឌីជីថលសម្រាប់ជនមានពិការភាពតាមរយៈសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធរួមមានជនមានពិការភាព ក្រសួង អ្នកពាក់ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

II. បង្កើតយុទ្ធនាការតស៊ូមតិតាមប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីបង្កើតចំណាប់អារម្មណ៍ទៅលើវិធីសាស្ត្របែបឌីជីថលចំពោះការចូលរួមរបស់ជនមានពិការភាព និងទាញយកមតិយោបល់បន្ថែមលើបញ្ហាប្រឈមពីជនមានពិការភាព និងសាធារណជននានា។

III. ជូនដំណឹង និងជះឥទ្ធិពលទៅកាន់អ្នកបង្កើតគោលនយោបាយអំពីលទ្ធផលទទួលបានដែលអាចក្លាយទៅជាដំណោះស្រាយដ៏ល្អប្រសើរមួយតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ។

## III. ការផ្លាស់ប្តូរបរិបទនៃគម្រោង

សិក្ខាសាលាបង្កើតរួមគ្នា ជាសកម្មភាពដំបូងនៃគម្រោងដែលបានប្រមូលផ្តុំភាគីពាក់ព័ន្ធសំខាន់ៗរួមមាន ជនមានពិការភាព តំណាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងគោលបំណង សម្របសម្រួលការពិភាក្សា កំណត់បញ្ហាប្រឈមសំខាន់ៗ និងបង្កើតដំណោះស្រាយទាក់ទងនឹងការចូលរួមបែប ឌីជីថលរបស់ជនមានពិការភាព។ ប៉ុន្តែបន្ទាប់ពីបញ្ចប់សិក្ខាសាលាចំនួន ២រួចមក យើងបានរកឃើញថាវិធីសាស្ត្រនៃការរៀបចំសិក្ខាសាលា និងទិសដៅនៃយុទ្ធនាការតស៊ូមតិតាមប្រព័ន្ធឌីជីថលចាំបាច់ត្រូវកែតម្រូវ។ ការរកឃើញបានបង្ហាញអំពីបញ្ហាផ្សេងៗដូចជា គណនេយ្យភាព ការបង្កលក្ខណៈងាយស្រួលសម្រាប់ការធ្វើដំណើរ និងការសម្របសម្រួលសមរម្យដែលផ្ទុយពីបញ្ហាឌីជីថលដូចបានរំពឹងទុក។ ហេតុនេះទើបធ្វើឲ្យមានការផ្លាស់ប្តូរពីយុទ្ធនាការដែលផ្តោតសំខាន់តែលើការចូលរួមបែបឌីជីថលទៅជាយុទ្ធនាការដែលបង្កើតការយល់ដឹងចំពោះការចូលរួមរបស់ជនមានពិការភាពទាំងក្នុងទិដ្ឋភាពឌីជីថល និងមិនមែនឌីជីថល។

## IV. លទ្ធផល

ការវិភាគឯកសារបានកំណត់ប្រធានបទនៃការចូលរួមរបស់ជនមានពិការភាពបឋមចំនួន ៤ ដូចជា ការអប់រំ អត្ថប្រយោជន៍សង្គម ការស្តារនីតិសម្បទា និងការងារ។

សិក្ខាសាលាបង្កើតរួមគ្នាត្រូវបានរៀបចំឡើងដើម្បីស្វែងយល់អំពីឧបសគ្គទាំងនេះ ប្រមូលផ្តុំការយល់ដឹង ក៏ដូចជាបំផុសគំនិតចំពោះដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតសម្រាប់ជនមានពិការភាព។ សិក្ខាសាលានីមួយៗក៏បានលើកទឹកចិត្តឲ្យមានការសហការ និងជម្រុញការសន្ទនាបើកចំហក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។

### a. ការអប់រំសម្រាប់ជនមានពិការភាព










### ការធ្វើដំណើរ

- **ឧបសគ្គ**: បញ្ហាប្រឈមទាក់ទងនឹងការធ្វើដំណើរត្រូវបានលើកឡើងដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ការសិក្សា និងចូលរួមសកម្មភាពជាក្រុមរបស់ជនមានពិការភាព។ ការលំបាកទាំងនេះត្រូវបានសន្មតជាចម្បងថាបណ្តាលមកពីតំបន់រស់នៅឆ្ងាយ និងបញ្ហាហិរញ្ញវត្ថុផងដែរ។

- **ដំណោះស្រាយដែលបានណែនាំ:**
    - គោលគំនិតក្នុងការបង្កើតឲ្យមានអន្តរវាសិកដ្ឋាននៅក្បែរគ្រឹះស្ថានអប់រំតាមរយៈការសហការរវាង ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវបានលើកឡើងដើម្បីដោះស្រាយបញ្ហាប្រឈមនេះ។
    - មធ្យោបាយធ្វើដំណើរសាធារណៈត្រូវបានស្នើឲ្យដាក់ប្រើប្រាស់នៅតាមបណ្ដាខេត្តដើម្បីធានាថាសិស្សមានពិការភាពមានលទ្ធភាពស្មើគ្នាក្នុងជម្រើសមធ្យោបាយធ្វើដំណើរ និងបង្កើនភាពចល័តរបស់ពួកគេនៅក្នុងសហគមន៍។

## ការបង្កលក្ខណៈងាយស្រួល

- **ឧបសគ្គ:** មានបញ្ហាប្រឈមដែលគួរឲ្យកត់សម្គាល់ចំពោះការប្រើប្រាស់ធនធាន និងសម្ភារៈបរិក្ខានានា ជាពិសេសការប្រើប្រាស់ជណ្ដើរទៅថ្នាក់រៀនជាន់ខាងលើ។ កង្វះផ្លូវជម្រាលស្ដង់ដារ និងការសម្របសម្រួលសមរម្យនៅក្នុងសាលារៀនបានធ្វើឲ្យការបង្កលក្ខណៈងាយស្រួលកាន់តែមានភាពស្មុគស្មាញ។ លើសពីនេះ សិស្សដែលមាន ពិការភាពគថ្លង់ក៏មានភាពលំបាកក្នុងការទទួលបានចំណេះដឹង និងជំនាញផងដែរ។

- **ដំណោះស្រាយដែលបានណែនាំ:**
    - តម្រូវការសម្រាប់ជម្រាលស្តង់ដារ និងសម្ភារៈបរិក្ខាដើម្បីសម្របសម្រួលសិស្សមានពិការភាពព្រមទាំងឧបករណ៍ជំនួយផ្សេងៗផ្អែកតាមប្រភេទពិការភាពត្រូវបានស្នើឡើងតាមរយៈការសហការរវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា។
    - ការថតសម្លេង និងកត់ចំណាំនៅលើទូរស័ព្ទដៃត្រូវបានស្នើសុំឲ្យប្រើប្រាស់អំឡុងពេលសិក្សាដើម្បីបង្កើនសមត្ថភាពសិក្សាឲ្យមានប្រសិទ្ធភាព និងបង្កលក្ខណៈងាយស្រួលសម្រាប់សិស្សមានពិការភាព។ ការសម្របសម្រួលទាំងនេះនឹងអនុញ្ញាតឲ្យពួកគេពិនិត្យមើលមេរៀនសំខាន់ៗទៅតាមល្បឿនរបស់ពួកគេ និងជៀសវាងការបាត់ព័ត៌មានលម្អិតនានាផងដែរ។
    - ដើម្បីសម្រួលដល់សិស្សដែលមានពិការភាពភ្នែក និងមានបញ្ហាប្រឈមក្នុងការអាន សេវាថែទាំសុខភាពភ្នែក និងការផ្ដល់វ៉ែនតាដោយឥតគិតថ្លៃត្រូវបានស្នើឡើង។ ធ្វើដូចនេះនឹងធានាឲ្យពួកគេ

ចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពសិក្សា ក៏ដូចជាអនុញ្ញាតឲ្យពួកគេប្រើប្រាស់ធនធាននានាប្រកបដោយប្រសិទ្ធភាព។

## លទ្ធភាពទទួលបានព័ត៌មាន

- **ឧបសគ្គ**: សិស្សមានពិការភាពប្រឈមនឹងបញ្ហាទទួលបានអាហារូបករណ៍ ដោយសារតែលក្ខខណ្ឌនៃការដាក់ពាក្យមិនមានភាពច្បាស់លាស់ដែលបង្កើតជាការធ្លាក់ទឹកចិត្តក្នុងការបន្តការសិក្សា។ លើសពីនេះ តំណាងរដ្ឋាភិបាលជាពិសេសនៅក្នុងថ្នាក់ភូមិ ឃុំ ខ្វះខាតព័ត៌មានទាក់ទងនឹងវិទ្យាល័យអប់រំពិសេសដែលធ្វើឲ្យការសម្របសម្រួលចំពោះធនធានសិក្សាមានកម្រិត ។ កង្វះព័ត៌មានបែបបរិយាបន្នទាំងនេះ កាន់តែរាំងដល់ការខិតខំប្រឹងប្រែងបំពេញតម្រូវការសិស្សមានពិការភាពដែលជះឥទ្ធិពលដល់ភាពជោគជ័យនៃការសិក្សារបស់ពួកគេ។
- **ដំណោះស្រាយដែលបានណែនាំ**:
  - តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន សិស្សមានពិការភាពត្រូវបានលើកទឹកចិត្តយ៉ាងសកម្មឲ្យបង្ហាញនូវតម្រូវការរបស់ពួកគេ។ ប្រធានភូមិ ឃុំត្រូវបានជម្រុញឲ្យចែករំលែកព័ត៌មានថ្មីៗជាប្រចាំជាមួយសហគមន៍ជនមានពិការភាព។លើសពីនេះសិស្សដែលមានពិការភាពត្រូវបានរំពឹងថានឹងអាចជួយផ្សព្វផ្សាយព័ត៌មានទាំងនោះទៅកាន់ជនមានពិការភាពដទៃទៀតផងដែរ។
  - លក្ខខណ្ឌពិការភាពត្រូវបានណែនាំឲ្យដាក់បញ្ចូលទៅក្នុងរាល់កម្មវិធី និង/ឬ ឱកាស សិក្សានានាដោយសហការជាមួយអង្គការពាក់ព័ន្ធ។ លើសពីនេះទៀត សិស្សដែលមានពិការភាពត្រូវបានលើកទឹកចិត្តឱ្យស្វែងរកព័ត៌មានអំពីកម្មវិធីសិក្សាឲ្យបានយ៉ាងសកម្មពីគ្រូរបស់ពួកគេ

## លទ្ធភាពឌីជីថល

- **ឧបសគ្គ**: ការពិភាក្សាត្រូវបានលើកឡើងអំពីបញ្ហាប្រឈមទាក់ទងនឹងប្រព័ន្ធឌីជីថលដែលជនមានពិការភាពបានជួបប្រទះដោយផ្តោតលើការទទួលបានព័ត៌មានអប់រំ ក៏ដូចជាកម្រិតចូលរួមក្នុងសកម្មភាពសង្គមដោយសារប្រព័ន្ធអ៊ីនធើណេតដំណើរការមិនប្រក្រតីជាពិសេសនៅតាមតំបន់ជនបទ។ កង្វះអក្ខរកម្មឌីជីថលត្រូវបានកំណត់ថាជាឧបសគ្គចម្បងដោយសង្កត់ធ្ងន់ថាប្រសិនបើគ្មានជំនាញចាំបាច់នានា សិស្សមានពិការភាពនឹងមានការលំបាកក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល និងធនធានអនឡាញផ្សេងៗប្រកបដោយ

ប្រសិទ្ធភាព។

- **ដំណោះស្រាយដែលបានណែនាំ:**
  - វិធីផ្សព្វផ្សាយបែបប្រពៃណីដូចជា ផ្ទាំងប៉ាណូ បដា និងផ្ទាំងរូបភាព ដើម្បីផ្សព្វផ្សាយយុទ្ធនាការអប់រំផ្សេងៗត្រូវបានស្នើឡើង ក៏ដូចជាការធ្វើការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំ និងរក្សាធនធានដែលសិស្សមានពិការភាពអាចចូលប្រើប្រាស់បាន។ តួនាទីរបស់សិស្សមានពិការភាពក៏ជាចលករដ៏សំខាន់ក្នុងការគាំទ្រគ្នាទៅវិញទៅមកផងដែរ។
  - ប្រៃសណីយ៍កម្ពុជា ត្រូវបានស្នើឱ្យពង្រីកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍របស់ខ្លួនដើម្បីផ្តល់លទ្ធភាពឱ្យជនមានពិការភាព និងប្រជាពលរដ្ឋនៅតាមជនបទអាចចូលប្រើប្រាស់បណ្ណាល័យអេឡិចត្រូនិកសម្រាប់តម្រូវការអប់រំរបស់ពួកគេ។
  - លើសពីនេះ ការផ្តល់កុំព្យូទ័រយួរដៃដែលមានផ្ទុកឯកសារអប់រំ និងការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនឹងសម្របសម្រួលសិស្សមានពិការភាពក្នុងការប្រើប្រាស់បណ្ណាល័យអេឡិចត្រូនិចប្រកបដោយប្រសិទ្ធភាព។

## សមត្ថភាពបង្រៀន

- **ឧបសគ្គ**: គម្លាតអក្ខរកម្មឌីជីថលរវាងគ្រូបង្រៀននៅតំបន់ប្រជុំជន និងនៅតាមជាយក្រុងអំពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេតត្រូវបានទទួលស្គាល់។ ភាពខុសគ្នានេះធ្វើឲ្យប៉ះពាល់ដល់វិធីសាស្ត្របង្រៀន និងការទំនាក់ទំនងជាមួយសិស្សមានពិការភាព។ លើសពីនេះ មានការព្រួយបារម្មណ៍អំពីកង្វះខាតគ្រូអប់រំពិសេស ជាពិសេសទាក់ទងនឹងការផ្លាស់ប្តូរតម្រូវការរបស់សិស្សដែលមានពិការភាពស្តាប់ដែលពួកគេអាចសិក្សាបានត្រឹមថ្នាក់ទី ៨ ដោយសារភាសាសញ្ញាមានការផ្លាស់ប្តូរ។

- **ដំណោះស្រាយដែលបានណែនាំ:**
  - គ្រូអប់រំពិសេសទាមទារការបណ្តុះបណ្តាលចំណេះដឹងពិការភាពកម្រិតខ្ពស់ដើម្បីផ្តល់ការសម្របសម្រួលសមរម្យ និងវិធីសាស្រ្តបង្រៀនសមស្របសម្រាប់សិស្សមានពិការភាព។
  - ការចូលរួមរបស់ឪពុកម្តាយក្នុងការបង្រៀនបំណិនជីវិតកម្រិតដំបូង ដូចជា ការហូបចុក ស្លៀកពាក់ និងអនាម័យខ្លួនប្រាណត្រូវបានស្នើឡើងដើម្បីគាំទ្រកុមារមានពិការភាព។ ការចូលរួមនេះក៏ត្រូវរាប់

បញ្ចូលនូវការគាំទ្រផ្នែកអារម្មណ៍ដើម្បីការពារពីបញ្ហាសុខភាពផ្លូវចិត្ត ក៏ដូចជាគាំទ្រដល់គ្រូអប់រំពិសេស។

- ការពង្រីកថ្នាក់អប់រំពិសេសដែលរួមបញ្ចូលកម្មវិធីថ្នាក់មត្តេយ្យអាចជាចលនាវិជ្ជមានសម្រាប់ការអន្តរាគមន៍ដំបូងចំពោះកុមារដែលមានពិការភាព។ វិធីសាស្រ្តនេះនឹងជួយសម្រួលដល់ការវិវឌ្ឍន៍យ៉ាងរលូនពីការអប់រំកុមារតូចៗទៅជាជំនួយបច្ចេកទេសដោយធានាថាពួកគេទទួលបានជំនួយ និងធនធានសំខាន់ៗភ្លាមៗតាំងពីដំបូង។

## សុខភាពផ្លូវកាយ ផ្លូវចិត្ត និងសុខុមាលភាព

- **ឧបសគ្គ**: ជនមានពិការភាពបានសង្កត់ធ្ងន់អំពីបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តចំពោះការអប់រំដោយលើកឡើងអំពីការរើសអើង និងការគាំទ្រដែលមានកម្រិតដែលរួមចំណែកដល់ការបាក់ទឹកចិត្តជាដើម។ ជាងនេះទៅទៀតសិស្សមានពិការភាពដែលមិនមានប័ណ្ណសមធម៌ជួបប្រទះនឹងបញ្ហាប្រឈមក្នុងការទទួលបានសេវាថែទាំសុខភាពដែលធ្វើឲ្យស្ថានភាព សុខភាពផ្លូវចិត្ត និងផ្លូវកាយកាន់តែមានសម្ពាធព្រមទាំងរារាំងដល់ការទទួលបានការអប់រំផងដែរ។

- **ដំណោះស្រាយដែលបានណែនាំ**:
    - ការអនុវត្តគំនិតផ្តួចផ្តើមទៅលើការយល់ដឹងអំពីពិការភាពនៅក្នុងសាលារៀន និងទីតាំងថែទាំសុខភាពត្រូវបានស្នើឡើងដោយសារគេជឿថាការអប់រំបុគ្គលិកសុខាភិបាលនឹងបង្កើនការគាំទ្រ និងការយល់ដឹងបន្ថែមសម្រាប់ជនមានពិការភាព។
    - តម្រូវការសម្រាប់ក្រសួងពាក់ព័ន្ធនានាក្នុងការលើកកម្ពស់ឲ្យមានមជ្ឈមណ្ឌលសុខភាពផ្លូវចិត្តដោយធានាឲ្យបាននូវការគាំទ្រផ្សេងៗសម្រាប់ជនមានពិការភាព។តាមរយៈការផ្តល់ការប្រឹក្សាបច្ចេកទេសនឹងធ្វើឲ្យសិស្សមានពិការភាពអាចកំណត់បញ្ហាប្រឈមដែលឈានទៅរកភាពប្រសើរឡើងនូវសុខុមាលភាព ភាគជោគជ័យក្នុងការសិក្សា និងការលូតលាស់ផ្ទាល់ខ្លួន។

## ៦. អត្ថប្រយោជន៍សង្គមសម្រាប់ជនមានពិការភាព










### លទ្ធភាពទទួលបានព័ត៌មាន

- **ឧបសគ្គ**: ការយល់ដឹងអំពីអត្ថប្រយោជន៍សង្គមក្នុងចំណោមប្រធានភូមិ ឃុំ មានការខ្វះខាត និងការផ្សព្វផ្សាយមានភាពមិនគ្រប់គ្រាន់។ ការណែនាំឲ្យបានច្បាស់លាស់ក្នុងដំណើរការស្នើសុំអត្តសញ្ញាណប័ណ្ណពិការភាពត្រូវបានសង្កត់ធ្ងន់។ កម្រិតអក្ខរកម្មរបស់ជនមានពិការភាពក៏ធ្វើឲ្យមានភាពស្មុគស្មាញដល់ការយល់ដឹង និងការប្រើប្រាស់សេវាគាំពារសង្គមផងដែរ។ លើសពីនេះ និយោជិកមានពិការភាពដែលធ្វើការក្នុងក្រុមហ៊ុនដែលមិនបានចុះបញ្ជីជួបការលំបាកក្នុងការទទួលបានសេវាបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដោយសារកង្វះព័ត៌មានពីនិយោជកដែលបង្កឲ្យជនមានពិការភាពខ្វះការយល់ដឹងអំពីសិទ្ធិរបស់ពួកគេ។

- **ដំណោះស្រាយដែលបានណែនាំ**:
  - លើកកម្ពស់ការយល់ដឹងអំពីអនុក្រឹត្យលេខ 108 ដែលទាក់ទងនឹងនីតិវិធីកំណត់អត្តសញ្ញាណ និងលក្ខណៈវិនិច្ឆ័យនៃការងារតាមរយៈសិក្ខាសាលាប្រចាំឆ្នាំ ឬវគ្គបណ្តុះបណ្តាលផ្សេងៗ។ គំនិតផ្តួចផ្តើមនេះមានគោលបំណងលើកកម្ពស់ចំណេះដឹងសម្រាប់និយោជក និងបុគ្គលិកដែលមានពិការភាពដោយធានាឲ្យបានថាពួកគេទទួលបានព័ត៌មានចាំបាច់ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព។
  - ប្រើប្រាស់ផ្ទាំងផ្សាយពាណិជ្ជកម្មដើម្បីផ្សព្វផ្សាយលេខទំនាក់ទំនង (MOSVY: 1270 និង NSSF: 1286) សម្រាប់សកម្មភាពផ្សព្វផ្សាយសហគមន៍ដើម្បីបង្កើនការយល់ដឹងអំពីធនធានដែលមាន។
  - អនុសាសន៍ក្នុងការរៀបចំព្រឹត្តិការណ៍ ឬសិក្ខាសាលាដែលផ្តោតលើសេវាគាំពារសង្គមឲ្យបានទៀតទាត់សម្រាប់ជនមានពិការភាពត្រូវបានលើកឡើង។ គំនិតផ្តួចផ្តើមនេះមានគោលបំណងអប់រំជនមានពិការភាពអំពីសិទ្ធិរបស់ពួកគេ ក៏ដូចជាការគាំទ្រនានាដែលមាន។ លើសពីនេះ កម្មវិធីផ្សព្វផ្សាយព័ត៌មាន សកម្មភាពផ្សព្វផ្សាយក្នុងសហគមន៍ និងខិតប័ណ្ណត្រូវបានកំណត់ថាជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការជូនដំណឹងដល់សហគមន៍អំពីធនធានទាំងនេះ។
  - ការប្រើប្រាស់មេក្រូធំៗនៅក្នុងសហគមន៍ត្រូវបានស្នើឡើងដើម្បីធានាបាននូវការផ្សព្វផ្សាយព័ត៌មានឲ្យកាន់តែទូលំទូលាយ។ គំនិតផ្តួចផ្តើមនេះគួរតែត្រូវបានអនុវត្តតាមរយៈកិច្ចសហការរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាជ្ញាធរមូលដ្ឋាន។
  - ការដាក់បញ្ចូលព័ត៌មានលម្អិតនៃសេវាគាំពារសង្គមទៅក្នុងកម្មវិធីសិក្សាត្រូវបានស្នើឡើង។ គំនិតផ្តួចផ្តើមនេះមានគោលបំណងអប់រំសិស្សអំពីសិទ្ធិ និងតម្រូវការរបស់ជនមានពិការភាពចាប់តាំងពីដំណាក់កាលដំបូងដើម្បីលើកកម្ពស់បរិយាបន្ន និងកាត់បន្ថយការមាក់ងាយផ្សេងៗ។

## លទ្ធភាពឌីជីថល

- **ឧបសគ្គ**: លទ្ធភាពប្រើប្រាស់ប្រព័ន្ធឌីជីថលមិនត្រូវបានមើលឃើញថាជាប្រឈមខ្លាំងនោះទេ។ ទោះជាយ៉ាងណា មានការទទួលស្គាល់ពីសារៈសំខាន់របស់វានៅពេលដែលការប្រើប្រាស់ឌីជីថលកំពុងកើនឡើង។ ក្នុងនោះ ក៏មានការលើកឡើងពីតម្រូវការក្នុងការសម្របសម្រួលលើប្រព័ន្ធឌីជីថលសម្រាប់អត្ថប្រយោជន៍សង្គម និងបញ្ហាប្រឈមនានាដែលទាក់ទង

នឹងការប្រមូលទិន្នន័យឌីជីថលសម្រាប់ជនមានពិការភាពដើម្បីធានាឲ្យបាននូវការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព។

- **ដំណោះស្រាយដែលបានណែនាំ**: វាពិតជាមានសារៈសំខាន់សម្រាប់អាជ្ញាធរមូលដ្ឋានសហការជាមួយជនមានពិការភាពក្នុងការទទួលការបណ្តុះបណ្តាលបន្ថែមដើម្បីប្រើប្រាស់កម្មវិធីរបស់រដ្ឋាភិបាល និងវិធីសាស្ត្រកំណត់អត្តសញ្ញាណជនមានពិការភាព។

## ការរើសអើងក្នុងសង្គម

- **ឧបសគ្គ**: ជនមានពិការភាពប្រឈមមុខនឹងការរើសអើងពីអ្នកផ្តល់សេវាដែលជារឿយៗធ្វេសប្រហែសពីតម្រូវការរបស់ពួកគេនៅពេលដែលប្រើប្រាស់សេវាសំខាន់ៗ។ ផ្ទុយទៅវិញ គេជឿថាជនមានពិការភាពមានការបាក់ទឹកចិត្តក្នុងការស្វែងរកសេវាគាំពារសង្គមដោយសារតែពួកគេយល់ឃើញថាសេវាគ្មានប្រសិទ្ធភាព ឬក៏ពួកគេមិនអាចទទួលបានសេវាទាំងនោះឡើយ។

- **ដំណោះស្រាយដែលបានណែនាំ**: អនុសាសន៍ក្នុងការបង្កើតបញ្ជរ ឬទីតាំងជាក់លាក់សម្រាប់ជនមានពិការភាពនៅតាមមណ្ឌល/ស្ថាប័នត្រូវបានស្នើឡើង។ វិធានការនេះនឹងធានាថាពួកគេទទួលបានការយកចិត្តទុកដាក់ និងការសម្របសម្រួលសមរម្យ។

## សមត្ថភាពសម្របសម្រួលសេវាកម្ម

- **ឧបសគ្គ**: ជនមានពិការភាពបានលើកឡើងអំពីការរង់ចាំរយៈពេល ៣ឆ្នាំក្នុងការទទួលបានអត្តសញ្ញាប័ណ្ណពិការភាព ដែលឆ្លុះបញ្ចាំងពីភាពយឺតយ៉ាវនៃសេវាគាំពារសង្គម។ តម្រូវការសម្រាប់ការកែលម្អ និងព័ត៌មានអត្ថប្រយោជន៍សង្គមមានកម្រិតពីអាជ្ញាធរមូលដ្ឋានត្រូវបានសង្កត់ធ្ងន់។ បញ្ហាទាំងនេះត្រូវបានទទួលស្គាល់ដោយលើកឡើងពីកង្វះចំណេះដឹងអំពីពិការភាព និងធនធានចុះឈ្មោះមិនគ្រប់គ្រាន់នៅថ្នាក់ភូមិ និងឃុំ។

- **ដំណោះស្រាយដែលបានណែនាំ**:
  - សារៈសំខាន់នៃការពង្រឹងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានត្រូវបានទទួលស្គាល់។ ក្នុងនោះក៏មានការលើកឡើងអំពីការផ្តល់ការបណ្តុះបណ្តាលសមត្ថភាពបន្ថែមសម្រាប់មន្ត្រីដែលធ្វើការកំណត់អត្ត-សញ្ញាណជនមានពិការភាព និងការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាលសម្រាប់ការចុះឈ្មោះ។ វគ្គបណ្តុះបណ្តាលនេះមានគោល

បំណងផ្តល់សិទ្ធិអំណាចដល់មន្ត្រីដើម្បីធ្វើបច្ចុប្បន្នភាព និងរក្សាស្ថិតិជនមានពិការភាពឲ្យបានត្រឹមត្រូវ។

- ○ មានការស្នើសុំឲ្យអាជ្ញាធរភូមិ ឃុំធ្វើការចុះឈ្មោះដោយផ្ទាល់នៅទីតាំងរបស់ជនមានពិការភាពដោយលើកឡើងពីបញ្ហាផាសុកវត្ថុ។ ការបង្កើនថវិកាជាតិ និងផែនការការងារសម្រាប់អាជ្ញាធរមូលដ្ឋានក៏មានសារៈសំខាន់ដើម្បីអនុវត្តដំណោះស្រាយទាំងនេះប្រកបដោយប្រសិទ្ធភាព។
- ○ ការបង្កើតពេងពុម្ពនៅតាមបណ្តាខេត្តក្រុងដើម្បីពន្លឿនការផលិតអត្តសញ្ញាណប័ណ្ណពិការភាពត្រូវបានស្នើឡើង។ គំនិតផ្តួចផ្តើមនេះមានគោលបំណងកាត់បន្ថយពេលវេលាដែលត្រូវរង់ចាំដើម្បីទទួលបានអត្តសញ្ញាណប័ណ្ណ។
- ○ ទីតាំងដាច់ដោយឡែកសម្រាប់ការទទួលបានសេវាគាំពារសង្គមត្រូវបានស្នើសុំដើម្បីធានាបាននូវជំនួយ និងការគាំទ្រភ្លាមៗដោយមិនមានការពន្យាពេលរង់ចាំ ឬស្ថិតក្នុងបរិយាកាសដែលមានមនុស្សច្រើនកុះករ។

## ផាសុកវត្ថុ

- **ឧបសគ្គ**: ជនមានពិការភាពប្រឈមនឹងការលំបាកក្នុងការទទួលបានសេវាគាំពារសង្គមដោយសារហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈបរិក្ខារមិនគ្រប់គ្រាន់នៅតាមសាលាភូមិ ឃុំ។ កង្វះជម្រាលផ្លូវស្តង់ដារ និងបន្ទប់ទឹកដែលមិនបានសាងសង់តាមស្តង់ដារផាសុកវត្ថុក៏ត្រូវបានសង្កត់ធ្ងន់ផងដែរ។ លើសពីនេះកង្វះថវិកាគាំទ្រសម្រាប់ការធ្វើដំណើរក៏បានរារាំងលទ្ធភាពក្នុងការចូលរួមយ៉ាងពេញលេញ និងទទួលបានសេវាចាំបាច់ផងដែរ។

- **ដំណោះស្រាយដែលបានណែនាំ**: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាគួរកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតាមសាលាភូមិ ឃុំឲ្យស្របតាមស្តង់ដារផាសុកវត្ថុ។

## ៤. សេវាស្តារនីតិសម្បទាសម្រាប់ជនមានពិការភាព










### លទ្ធភាពក្នុងការធ្វើដំណើរ

- **ឧបសគ្គ៖** ជនមានពិការភាពជួបការលំបាកក្នុងការទទួលបានសេវាស្តារនីតិសម្បទាជាប្រចាំដោយសារតំបន់រស់នៅឆ្ងាយ មធ្យោបាយធ្វើដំណើរមានកម្រិត និងការគាំទ្រផ្នែកហិរញ្ញវត្ថុដែលរួមផ្សំដោយបញ្ហាប្រឈមនៃការធ្វើដំណើរតែម្នាក់ឯង។

- **ដំណោះស្រាយដែលបានណែនាំ:** ការធ្វើសមាហរណកម្មនៃសេវាស្តារនីតិសម្បទាទៅក្នុងមណ្ឌលសុខភាពសហគមន៍ត្រូវបានសង្កត់ធ្ងន់ដើម្បីកែលម្អលទ្ធភាពប្រើប្រាស់សម្រាប់ជនមានពិការភាព និងបង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## លទ្ធភាពទទួលបានព័ត៌មាន

- **ឧបសគ្គ៖** ជនមានពិការភាពបានគូសបញ្ជាក់ពីកង្វះព័ត៌មានស្តារនីតិសម្បទានៅក្នុងសហគមន៍មូលដ្ឋានដោយកត់សម្គាល់ថាកិច្ចប្រជុំទាក់ទងនឹងពិការភាពមិនត្រូវបានផ្តល់អាទិភាពនៅថ្នាក់ភូមិ ឃុំនោះទេ។ ឧបសគ្គទាក់ទងនឹងកង្វះព័ត៌មានអាចបណ្តាលមកពីវ័យរបស់អាជ្ញាធរមូលដ្ឋាន និងវិធីសាស្រ្តផ្សព្វផ្សាយបែបប្រពៃណីដែលមិនមានប្រសិទ្ធភាព។ ការផ្សព្វផ្សាយព័ត៌មានថ្មីៗនៃសេវាស្តារនីតិសម្បទាទាមទារពេលវេលា និងធនធានដែលជាបញ្ហាប្រឈមសម្រាប់តំបន់ជនបទ។ លើសពីនេះ ការរើសអើងក៏កើតឡើងនៅក្នុងលទ្ធភាពទទួលបានព័ត៌មានអំពីសេវាស្តារនីតិសម្បទាផងដែរ។

- **ដំណោះស្រាយដែលបានណែនាំ**:
  - មានការស្នើឲ្យប្រើប្រាស់មេក្រូធំៗនៅតាមសហគមន៍មូលដ្ឋានដើម្បីផ្សព្វផ្សាយព័ត៌មានអំពីសេវាស្តារនីតិសម្បទាជាពិសេសសម្រាប់អ្នករស់នៅតំបន់ដាច់ស្រយាល។ វិធីសាស្រ្តនេះមានគោលបំណងពង្រីកឲ្យបានទូលំទូលាយទៅដល់សាធារណជន និងធានាថាព័ត៌មានសំខាន់ៗត្រូវបានចែករំលែកប្រកបដោយប្រសិទ្ធភាព។
  - ការប្រើប្រាស់កម្មវិធីតេឡេក្រាម (Telegram) ដើម្បីផ្សព្វផ្សាយព័ត៌មានក៏អាចជាប្រយោជន៍សម្រាប់ប្រធានភូមិ ឃុំដែលមានវ័យចំណាស់ផងដែរ។
  - មានការស្នើឲ្យបង្កើតបណ្តាញជនមានពិការភាពដើម្បីបង្កើនការផ្សព្វផ្សាយព័ត៌មានដោយសារពួកគេដើរតួជាប្រភពដ៏សំខាន់នៃការបំផុសគំនិតសម្រាប់អ្នកដទៃទៀតដែលប្រឈមមុខនឹងបញ្ហាស្រដៀងគ្នានេះ។ ម្យ៉ាងទៀត ក៏មានការស្នើឲ្យមានការចូលរួមពីអ្នកស្ម័គ្រចិត្តក្នុងមណ្ឌលសុខភាពសហគមន៍ដើម្បីផ្សព្វផ្សាយអំពីសេវាស្តារនីតិសម្បទា។
  - វគ្គបណ្តុះបណ្តាលរយៈពេលខ្លីសម្រាប់ប្រធានភូមិ តាមរយៈការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលក៏ត្រូវបានស្នើឡើងផងដែរ។
  - ការរៀបចំសិក្ខាសាលាដែលផ្តោតលើការប្រយុទ្ធប្រឆាំងនឹងការរើសអើងចំពោះជនមានពិការភាពក៏អាចជួយអប់រំសមាជិកក្នុងសហគមន៍

អំពីសិទ្ធិ និងសមត្ថភាពរបស់ពួកគេស្របពេលកាត់បន្ថយការមាក់ងាយចំពោះពិការភាពផងដែរ។

## ជំនឿផ្ទាល់ខ្លួន និងឥទ្ធិពលនៃបរិយាកាសជុំវិញ

- **ឧបសគ្គ៖** ការយល់ឃើញដែលមានលក្ខណៈតូចចង្អៀតអំពីសមត្ថភាពរបស់ជនមានពិការភាព កង្វះការអប់រំអំពីសិទ្ធិ និងការយល់ខុសអំពីសេវាស្តារនីតិសម្បទារារាំងជនមានពិការភាពពីការទទួលបានសេវាប្រកបដោយប្រសិទ្ធភាព។ ឧបសគ្គទាំងនេះបង្កជាការខកខានការពិនិត្យសុខភាព និងធ្វើឲ្យមានគម្លាតទំនាក់ទំនងដែលរារាំងដល់ការផ្តល់សេវាទាន់ពេលវេលា។
- **ដំណោះស្រាយដែលបានណែនាំ**: ការតស៊ូមតិសម្រាប់ការផ្តល់ប្រឹក្សាលើកទឹកចិត្តត្រូវបានស្នើឲ្យមានដោយសហការជាមួយក្រុមគ្រួសារ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក៏ដូចជាលើកកម្ពស់ការគាំទ្រពីមិត្តភក្តិ។

## សមត្ថភាពសម្របសម្រួលរបស់អ្នកផ្តល់សេវា

- **ឧបសគ្គ៖** អ្នកផ្តល់សេវាស្តារនីតិសម្បទាប្រឈមមុខនឹងបញ្ហាដូចជាភាពធ្វេសប្រហែសពីអាជ្ញាធរភូមិ ឃុំ ភាពលំបាកក្នុងការសម្របសម្រួលឧបសគ្គផ្នែកហិរញ្ញវត្ថុ ការជ្រើសរើសបុគ្គលិក និងកង្វះឧបករណ៍ព្យាបាលកាយសម្បទានៅក្នុងមន្ទីរពេទ្យមួយចំនួន។
- **ដំណោះស្រាយដែលបានណែនាំ**:
  - មានការទាមទារឲ្យមានការលើកកម្ពស់ការអប់រំ ក្នុងគោលបំណងជូនដំណឹងដល់សហគមន៍ជនមានពិការភាព និងគ្រួសាររបស់ពួកគេអំពីសិទ្ធិដែលពួកគេមានតាមរយៈការសហការជាមួយអាជ្ញាធរភូមិ ឃុំ។
  - ដើម្បីកែលម្អការតាមដានលើការទទួលសេវាស្តារនីតិសម្បទា មានការស្នើឲ្យជ្រើសរើសបុគ្គលិកបន្ថែមទៀតតាមរយៈការសហការជាមួយអាជ្ញាធរមូលដ្ឋាន។
  - អនុសាសន៍ក្នុងការពិគ្រោះយោបល់ទូទាំងប្រទេសជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវបានស្នើឡើងដើម្បីប្រមូលធាតុចូល និងមតិកែលម្អឲ្យបានទូលំទូលាយចំពោះគំនិតផ្តួចផ្តើមនានា។

## ៨. លទ្ធភាពទទួលបានការងារសម្រាប់ជនមានពិការភាព










### ឧបសគ្គសង្គម និងឧបសគ្គស្ថាប័ន

- **ឧបសគ្គ៖** ជនមានពិការភាពជួបប្រទះនឹងឧបសគ្គដូចជាការរើសអើង កង្វះការសម្របសម្រួល និងលក្ខណៈវិនិច្ឆ័យការងារមិនច្បាស់លាស់ដែលធ្វើឲ្យពួកគេពិបាកស្វែងរកការងារ។ ការឲ្យតម្លៃលើប្រាក់ចំណេញរបស់ក្រុមហ៊ុនឯកជនជារឿយៗនាំឲ្យមានការរារាំងដល់ជនមានពិការភាពដែលរួមចំណែកដល់ការមិនដាក់បញ្ចូលពួកគេ និងបង្កើតភាពលំបាកក្នុងការទទួលបានឱកាសការងារ។

- **ដំណោះស្រាយដែលបានណែនាំ**:
  - មានការស្នើឲ្យកែលម្អកិច្ចសហប្រតិបត្តិការ និងការអនុវត្តច្បាប់នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) រួមទាំងកែសម្រួលការផាកពិន័យចំពោះការមិនអនុលោមតាមច្បាប់ដើម្បីធានាឲ្យបាននូវការ

អនុវត្តប្រកបដោយប្រសិទ្ធភាពក៏ដូចជាប្រើប្រាស់ធនធានពីការផាក ពិន័យដើម្បីគាំទ្រគំនិតផ្តួចផ្តើមផ្សេងទៀតសម្រាប់ជនមានពិការភាព នាពេលអនាគត។

  - ការដាក់បញ្ចូលសមត្ថភាពរបស់ជនមានពិការភាពទៅក្នុងទិន្នន័យ ពិការភាពនឹងសម្រួលដល់ក្រុមហ៊ុនឯកជនដែលមានចំណាប់ អារម្មណ៍ស្វែងរកបុគ្គលិកមានពិការភាពឲ្យកាន់តែមានភាព ងាយស្រួល។
  - និយោជកគួរបំពេញតាមតម្រូវការរបស់ជនមានពិការភាពដើម្បី បង្កើតបរិយាកាសការងារបែបបរិយាបន្នឲ្យកាន់តែច្រើន ព្រមទាំង បណ្តុះបណ្តាលបុគ្គលិកដែលគ្មានពិការភាពដើម្បីកាត់បន្ថយការ រើសអើង។

## ផាសុកវត្ថុ

- **ឧបសគ្គ៖** ផាសុកវត្ថុនៅកន្លែងធ្វើការសម្រាប់ជនមានពិការភាព ជាពិសេស នៅក្នុងអាជីវកម្មឯកជននៅមានភាពខ្វះខាតដូចជាបន្ទប់ទឹក ជម្រាល ជណ្តើរយន្ត និងទីធ្លាចេញចូលមិនធំទូលាយ។ កត្តាទាំងអស់នេះបានរាំង ឱកាសការងារ ក៏ដូចជាបរិយាបន្នសម្រាប់ជនមានពិការភាពដែលកំពុង ស្វែងរកការងារ។

- **ដំណោះស្រាយដែលបានណែនាំ**: មានការស្នើឲ្យលើកទឹកចិត្តទាំងតំណាង រដ្ឋាភិបាល និងតំណាងឯកជនឲ្យផ្តល់អាទិភាពព្រមទាំងបង្កើតផាសុកវត្ថុឲ្យ បានទូលំទូលាយដូចជា បន្ទប់ទឹកទូលំទូលាយ ជម្រាល និងសម្ភារៈបរិក្ខារ ផ្សេងទៀតដើម្បីបង្កើតបរិយាកាសដែលមានបរិយាបន្ន និងបង្កលក្ខណៈ ងាយស្រួលសម្រាប់ជនមានពិការភាព។

## លទ្ធភាពទទួលបានព័ត៌មាន

- **ឧបសគ្គ៖** សកម្មភាពលើកកម្ពស់គោលនយោបាយដែលមានអត្ថប្រយោជន៍ សម្រាប់ជនមានពិការភាពនៅមានភាពខ្វះខាតជាពិសេសក្នុងការចែករំលែក ព័ត៌មានការងារដោយសារបណ្តាញទំនាក់ទំនង និងប្រព័ន្ធអ៊ីនធើណេតនៅ មានកម្រិតតាមតំបន់ជនបទ។

- **ដំណោះស្រាយដែលបានណែនាំ**: ការបែងចែកធនធានដើម្បីរៀបចំសិក្ខាសាលា និងផលិតការបោះពុម្ពផ្សព្វផ្សាយដោយប្រើប្រាស់ថវិកាមួយចំនួនពិតជាមានសារៈសំខាន់ក្នុងគោល បំណងដោះស្រាយគម្លាតព័ត៌មាន។

## ចំណេះដឹងអំពីពិការភាព

- **ឧបសគ្គ៖** ចំណេះដឹងអំពីពិការភាពដែលមានកម្រិត បានបង្កើតឲ្យមានកង្វះការស្វែងយល់អំពីជនមានពិការភាព។ ជារឿយៗគ្រួសារនីមួយៗជឿថាលទ្ធភាពស្វែងរកការងារសម្រាប់ជនមានពិការភាពគឺសឹងតែមិនអាចទៅរួចដោយសារតែពិការភាពរបស់ពួកគេ។ ម៉្យាងវិញទៀត ការមើលថែទាំជនមានពិការភាពលើសលប់ក៏បានរារាំងការអនុញ្ញាតឲ្យពួកគេចូលរួមក្នុងសង្គម។ ការព្រួយបារម្ភអំពីសមត្ថភាពរបស់ពួកគេ និងភាពភ័យខ្លាចចំពោះការរើសអើងក៏បន្តបង្អាក់ក្រុមគ្រួសារក្នុងការគាំទ្រជនមានពិការភាពឲ្យចូលរួមក្នុងសកម្មភាពសង្គមផងដែរ។
- **ដំណោះស្រាយដែលបានណែនាំ**:
  - ក្រុមហ៊ុន និងស្ថាប័នឯកជនត្រូវបានស្នើឲ្យចូលរួមក្នុងការបណ្តុះបណ្តាលអំពីពិការភាពដើម្បីបង្កើនការយល់ដឹង និងការគាំទ្រដល់បុគ្គលិកដែលមានពិការភាពនៅក្នុងកន្លែងធ្វើការ។
  - មានការស្នើឲ្យភាគីពាក់ព័ន្ធសំខាន់ៗរួមមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ដូចជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបន្តបង្កើនកិច្ចខិតខំប្រឹងប្រែងតស៊ូមតិដើម្បីសិទ្ធិរបស់ជនមានពិការភាព។ សកម្មភាពនេះ គួរតែផ្តោតលើការអប់រំគ្រួសារ និងអ្នកថែទាំឲ្យមានការយល់ដឹងអំពីពិការភាពកាន់តែប្រសើរឡើង។

## ជំនាញផ្ទុយទៅនឹងទីផ្សារការងារ

- **ឧបសគ្គ៖** ជនមានពិការភាពប្រឈមមុខនឹងបញ្ហាដូចជាកង្វះការយល់ដឹងអំពីសិទ្ធិ គ្មានទំនុកចិត្តលើខ្លួនឯងដោយសារបទដ្ឋានសង្គម និងការរើសអើង ក៏ដូចជាការគាំទ្រពីគ្រួសារនៅមានកម្រិតដែលធ្វើឲ្យពួកគេរើសអើងខ្លួនឯង។ កត្តាទាំងនេះប៉ះពាល់ដល់លទ្ធភាពទទួលបានការអប់រំ ជំនាញព្រមទាំងឱកាសការងារដែលរួមបញ្ចូលដោយបញ្ហាជីវភាព និងកង្វះការយល់ដឹងអំពីពិការភាពដែលរារាំងដល់ការតស៊ូមតិដោយខ្លួនឯង។

- **ដំណោះស្រាយដែលបានណែនាំ**: មានការជម្រុញឲ្យជនមានពិការភាពពង្រឹងសមត្ថភាពរបស់ខ្លួនដោយអភិវឌ្ឍជំនាញឲ្យបានច្រើនតាមរយៈបណ្តាញ និងស្វ័យសិក្សា។ អាជ្ញាធរមូលដ្ឋាន និងក្រសួងពាក់ព័ន្ធត្រូវបានលើកទឹកចិត្តឲ្យរៀបចំកម្មវិធីបណ្តុះបណ្តាលឲ្យបានសមស្របនឹងតម្រូវការរបស់ជនមានពិការភាព។ លើសពីនេះ គួរតែផ្តល់ការសម្របសម្រួលសមរម្យ និងកែលម្អលទ្ធភាពទទួលបានការអប់រំសម្រាប់ពួកគេ។

បញ្ជាក់: លទ្ធផលទាំងនេះត្រូវបានរកឃើញ និងសម្រេចជាចម្បងតាមរយៈការពិភាក្សាជាក្រុម ហើយមិនត្រូវបានចាត់ទុកជាបទពិសោធន៍ និងទស្សនៈរបស់ជនមានពិការភាពគ្រប់រូបនោះឡើយដោយសារនេះគ្រាន់តែជាគំនូសបញ្ជាក់ពីដំណោះស្រាយដែលអាចធ្វើទៅបានដើម្បីបង្ហាញពីភាពចម្រុះ។

# សេចក្តីបញ្ចប់នៃគម្រោង
# «ឌីជីថលសម្រាប់ទាំងអស់គ្នា : ការចូលរួមរបស់ជនមានពិការភាព តាមរយៈប្រព័ន្ធឌីជីថល»

ការចូលរួមរបស់ប្រជាពលរដ្ឋដែលមានលក្ខណៈបរិយាបន្នមានភាពចាំបាច់សម្រាប់ជនមានពិការភាព ព្រោះវានឹងផ្តល់សិទ្ធិអំណាចដល់ពួកគេក្នុងការសម្រេចចិត្ត ជម្រុញភាពជាកម្មសិទ្ធិ និងសុខុមាលភាព បង្កើតបរិយាកាសជាសុករវត្ត លើកកម្ពស់ការយល់ដឹង និងបង្កើតបរិយាបន្ននៅក្នុងសង្គម។ តាមរយៈការចូលរួមពីបុគ្គលដែលមានបទពិសោធន៍មកពីគ្រប់មជ្ឈដ្ឋាននៅក្នុងដំណើរការសម្រេចក៏ដូចជាសកម្មភាពសហគមន៍នឹងធ្វើឲ្យការចូលរួមរបស់ប្រជាពលរដ្ឋបែបបរិយាបន្នមានភាពសមធមមិជាងមុនដែលគ្រប់មតិយោបល់ត្រូវបានស្តាប់ ឲ្យតម្លៃ និងតំណាង។

ដំណោះស្រាយរួមនេះដើរតួជាកាតាលីករសម្រាប់ការផ្លាស់ប្តូរវិជ្ជមាន បង្រួមគម្លាត និងបំបែករនាំងដែលរារាំងដល់ ការចូលរួម និងបរិយាបន្ន។ ទោះបីជាលទ្ធផលត្រូវបានបង្កើតឡើងដោយចម្បងពីការពិភាក្សាជាក្រុម និងមិនអាចឆ្លុះ បញ្ចាំងយ៉ាងទូលំទូលាយអំពីបទពិសោធន៍ និងទស្សនៈរបស់ជនមានពិការភាពគ្រប់រូបក៏ដោយ ទស្សនៈចម្រុះទាំងនេះនៅតែបង្កើតជាការយល់ដឹង និងអនុសាសន៍ដ៏មានតម្លៃសម្រាប់ការបង្កើតបរិយាកាសបែបបរិយាបន្នសម្រាប់ជនមានពិការភាព។ នេះជាការចាប់ផ្តើមនៃការផ្លាស់ប្តូរដ៏អស្ចារ្យជាមួយអ្នកបង្កើតគោលនយោបាយ អង្គការ និងសហគមន៍ដែលចូលរួមសហការ ហើយយើងជឿជាក់ថានៅមានកិច្ចការជាច្រើនទៀតដើម្បីធានាថាជនមានពិការភាពអាចចូលរួមយ៉ាងពេញលេញនៅក្នុងសង្គម និងទទួលបានឱកាសស្មើគ្នានៅគ្រប់ទិដ្ឋភាពនៃជីវិត។

គម្រោង «ឌីជីថលសម្រាប់ទាំងអស់គ្នា : ការចូលរួមរបស់ជនមានពិការភាពតាមរយៈប្រព័ន្ធឌីជីថល» ទទួលបានការគាំទ្រថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈគម្រោង គាំទ្រអង្គការសង្គមស៊ីវិល (CSS) នៃអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360) និងសហការអនុវត្តដោយ សហគ្រាសសង្គម អ៊ែជ្យាយល៍ (Agile Development Group) ចាប់ពីខែតុលា ឆ្នាំ២០២៣ ដល់ខែ កក្កដា ឆ្នាំ២០២៤ ក្នុងគោលបំណងបង្កើនការចូលរួមរបស់ជនមានពិការភាពប្រកបដោយបរិយាបន្នដោយ លើកកម្ពស់ការយល់ដឹង អំពីយុទ្ធសាស្ត្រចូលរួមរបស់ប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថល ជម្រុញឲ្យមានការផ្លាស់ប្តូរ អាកប្បកិរិយា ក៏ដូចជាជះឥទ្ធិពលទៅកាន់អ្នកបង្កើតគោលនយោបាយអំពីអក្ខរកម្មឌីជីថល និងការសម្របសម្រួលសមរម្យសម្រាប់បរិយាបន្នជនមានពិការភាព។